# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ខ្ញុំបាទឈ្មោះ **សេង លាង** មន្ត្រីការិយាល័យអភិរក្សជលផលនៃនាយកដ្ឋានអភិរក្សជលផល។

**<u>សូមគោរពជូន</u>**

**លោកប្រធាននាយកដ្ឋានអភិរក្សជលផល**

**<u>កម្មវត្ថុ</u>** : របាយការណ៍ស្តីពី " ការប្រជុំពិភាក្សាពិគ្រោះយោបល់ដើម្បីឈានទៅបោះបង្គោលកំណត់ព្រំប្រទល់តំបន់ការពារព្រៃកោងកាង និងសាងសង់ប៉មយាមរបស់កម្មវិធីREDD+កម្ពុជា នៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ "។

**<u>យោង</u>** : លិខិតបេសកកម្មលេខ ៤២៦ ជ.ផ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០១៤ របស់រដ្ឋបាលជលផល។

ន័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ក្រុមការងារយើងខ្ញុំសូមរាយការណ៍ជូនលោកប្រធានមេត្តាជ្រាបដូចខាងក្រោម ៖

**១-គោលបំណង**

គោលបំណង គឺពិភាក្សាពិគ្រោះយោបល់ជាមួយខណ្ឌរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន និងសហគមន៍នេសាទពាក់ព័ន្ធ ដើម្បីកំណត់ទីតាំងជាក់លាក់សម្រាប់បោះបង្គោល និងសាងសង់ប៉មយាមនៅតំបន់គ្រប់គ្រងព្រៃកោងកាងព្រៃនប់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

**២-សកម្មភាពការងារ**

នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៤ ក្រុមការងាររបស់នាយកដ្ឋានអភិរក្សជលផលនៃរដ្ឋបាលជលផល មន្ត្រីខណ្ឌរដ្ឋបាលជលផលកំពង់សោម អាជ្ញាធរមូលដ្ឋាន និងសហគមន៍នេសាទពាក់ព័ន្ធ បានបើកកិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់ដើម្បីកំណត់ទីតាំងជាក់លាក់សម្រាប់បោះបង្គោល និងសាងសង់ប៉មយាមនៅតំបន់គ្រប់គ្រងព្រៃកោងកាងព្រៃនប់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ អង្គប្រជុំបានពិភាក្សាទៅលើទីតាំងដែលបានចុះយកនិយាមកាសម្រាប់បោះបង្គោល និងសាងសង់ប៉មយាម ដែលបានកំណត់កាលពីកិច្ចពិភាក្សាពិគ្រោះយោបល់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ កន្លងមក។

**៤-សមាសភាពចូលរួម**

សមាសភាពចូលរួមសរុបចំនួន ១៣ រូប មកពី ៖

| | |
|---|---|
| - ក្រុមការងារនាយកដ្ឋានអភិរក្សជលផលនៃរដ្ឋបាលជលផល | ០២ រូប |
| - នាយរងខណ្ឌរដ្ឋបាលជលផលជលផលកំពង់សោម | ០១ រូប |
| - ផ្នែករដ្ឋបាលជលផលព្រៃនប់ | ០១ រូប |
| - សង្កាត់រដ្ឋបាលជលផលកោះខ្យង | ០១ រូប |
| - មេឃុំអូរឧកញ៉ាហេង មេឃុំទូលទទឹង មេឃុំព្រៃនប់ និងបឹងតាព្រហ្ម | ០៤ រូប |
| - ក្រុមប្រឹក្សាឃុំអូរឧកញ៉ាហេង | ០១ រូប |
| - សហគមន៍នេសាទជំពូខ្មៅ សហគមន៍នេសាទបែកក្រង់ និងសហគមន៍នេសាទបឹងជុំ | ០៣ រូប |

**៥-លទ្ធផលការងារ**

ជាលទ្ធផល អង្គប្រជុំបានសម្រេចរំកិលទីតាំងបង្គោលត្រង់ចំណុចបត់ព្រែកទទឹង ព្រែកតាសុប ព្រែកតាហ៊ី ព្រែកបាញ់ជ្រូក និងព្រែកពង់ពាឲ្យមានចម្ងាយពី ១ ទៅ ៣ម៉ែត្រ នៅតាមបណ្តោយខ្នងទំនប់។ ចំណែកការសាងសង់ប៉មយាម អង្គប្រជុំបានសម្រេចយកទីតាំងចំណុចបត់កូនកុក។

**៦-ទិសដៅបន្ត**

ក្រុមការងារនាយកដ្ឋានអភិរក្សជលផលនៃរដ្ឋបាលជលផល នឹងធ្វើផែនទីបង្ហាញទីតាំងសម្រាប់បោះបង្គោល និងសាងសង់ប៉មយាមនៅតំបន់គ្រប់គ្រងព្រៃកោងកាងព្រៃនប់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ និងបន្តតាមដាននិងជម្រុញសកម្មភាពល្បាតរបស់ក្រុមល្បាតបន្តទៀត។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធានមេត្តាជ្រាបជារបាយការណ៍ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៤

អ្នកធ្វើរបាយការណ៍

សេង លាង

បានឃើញ និងឯកភាព

ប្រធាននាយកដ្ឋានអភិរក្សជលផល

# រូបភាពប្រជុំពិភាក្សាពិគ្រោះយោបល់ទីតាំងបោះបង្គោល និងសាងសងប៉មយាម
# នៅតំបន់គ្រប់គ្រងព្រៃកោងកាងព្រៃនប់
# ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៤









រូបភាពប្រជុំពិគ្រោះយោបល់នៅសាលាឃុំអូរឧកញ៉ាហេង





រូបភាពចុះបោះបង្គោលសម្គាល់សម្រាប់សាងសងប៉មយាម